**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប្រក

រាជធានី ភ្នំពេញ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦

# ប្រកាស
## ស្តីពី
## ការបង្កើត និងដាក់ឱ្យដំណើរការ ធីស្នាក់ការគយនិងរដ្ឋាករ ប្រចាំឃ្លាំង និងទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ តិច ស្រ៊ុន អ៊ឹមផត អ៊ិចផត និងគ្រេនស្តក
## ( ធីស្នាក់ការគយនិងរដ្ឋាករថៃស្តុក តិច ស្រ៊ុន )

*****

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ សេចក្តីជូនដំណឹងលេខ ១៦៣ សជណ ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញ ប្រកាសលេខ ០០៨ សហវ.គរ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតការិយាល័យគ្រប់គ្រងផែស្ងួត និងឃ្លាំងដែលគ្រប់គ្រងដោយគយ និង ទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ ✓

- យោងកិច្ចសន្យាស្តីពីការបង្កើត និងធ្វើអាជីវកម្មឃ្លាំងដែលគ្រប់គ្រងដោយគយ និងទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ ដែលផ្ទុកដោយកុងតឺន័រ រវាងទីចាត់ការគយនិងរដ្ឋាករ និងក្រុមហ៊ុនតិច ស្រ៊ុន អ៊ឹមផត អ៊ិចស្ពត និង ត្រេនស្ពត ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៦ ។
- យោងការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ ១:** បង្កើត និងដាក់ឱ្យដំណើរការនូវ ទីស្នាក់ការគយនិងរដ្ឋាករផែស្ងួត តិច ស្រ៊ុន ដែលស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

**ប្រការ ២:** ទីស្នាក់ការគយនិងរដ្ឋាករផែស្ងួត តិច ស្រ៊ុន ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ ។

**ប្រការ ៣:** ទីស្នាក់ការគយនិងរដ្ឋាករផែស្ងួត តិច ស្រ៊ុន មានភារកិច្ចដូចតទៅ ÷

- គ្រប់គ្រង និងត្រួតពិនិត្យទំនិញ ក្នុងទីតាំងផែស្ងួត លើគ្រប់ទំនិញនាំចេញក្រៅក្របខ័ណ្ឌវិនិយោគ និងទំនិញនាំចូលគ្រប់ប្រភេទ លើកលែងតែមានការអនុញ្ញាតដោយឡែកពីទីចាត់ការគយនិងរដ្ឋាករ។
- ចាត់តាំងក្រុមអនុរក្ស និង ក្រុមត្រួតពិនិត្យ លើកិច្ចប្រតិបត្តិការគ្រប់គ្រងទំនិញ នាំចេញ នាំចូល ដែលស្ថិតនៅក្នុងឃ្លាំង និងទីលានបញ្ចេញទំនិញ ក្នុងផែស្ងួតតិច ស្រ៊ុន លើទំនិញដូចចែងខាងលើ ។
- ត្រួតពិនិត្យ និងប្រមូលពន្ធ ចំពោះមុខទំនិញ នាំចូល នាំចេញ ដូចចែងខាងលើ និងអនុញ្ញាតឱ្យទំនិញចេញពីឃ្លាំង និងទីលានបញ្ចេញទំនិញពីគយនិងរដ្ឋាករ ក្រោយពីធ្វើការត្រួតពិនិត្យ និងបញ្ចប់បែបបទគយតាមបញ្ញត្តិច្បាប់ជាធរមាន ។

**ប្រការ ៤:** ប្រកាសទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥:** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធផ្សេងទៀត នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រសួងពាណិជ្ជកម្ម
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  « ដើម្បីជូនជ្រាប »
- ដូចប្រការ ៥ « ដើម្បីអនុវត្ត »
- ឯកសារ - កាលប្បវត្តិ

គាត ឈន់